**ធម្មទេសនារបស់លោកអតិបាលអូលីវីយេ**

**អតិបូជាបុណ្យព្រះយេស៊ូសម្តែងឋានៈព្រះអង្គនៅផ្សារតូច**

**ថ្ងៃទី០៨ មករា ២០១៧**

អត្ថបទទី១៖ អស ៦០,១-៦
អត្ថបទទី២៖ អភ ៣,២-៣ក.៥-៦
ដំណឹងល្អ៖ មថ ២,១-១២

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ ដែលយើងគោរពបុណ្យព្រះយេស៊ូសម្តែងឋានៈព្រះអង្គឲ្យមនុស្សលោកឃើញ មិនមែនឲ្យតែអ្នកដែលទៅថ្វាយបង្គំព្រះយេស៊ូនៅភូមិបេថ្លេហិម ប៉ុន្តែថ្ងៃនេះពិតមែនតាមរយៈហោរាចារ្យព្រះយេស៊ូបានសម្តែងឋានៈរបស់ព្រះអង្គឲ្យមនុស្សលោកឃើញ ឲ្យមនុស្សទាំងអស់អាចមើលឃើញព្រះយេស៊ូបាន។ នៅក្នុងអត្ថបទទីមួយ "**យេរូសាឡឹមអើយចូរក្រោកឡើង**" យើងឃើញព្រះបន្ទូលនេះគឺហោរាចារ្យបានអនុវត្តតែម្តង នៅពេលគេឃើញផ្កាយមួយពួកហោរាចារ្យនាំគ្នាធ្វើដំណើរពីទិសខាងកើតមកដល់ក្រុងយេរូសាឡឹម។ នៅពេលយើងចង់ដើរតាមព្រះយេស៊ូ នៅពេលយើងចង់ដើរតាមព្រះបន្ទូលដែលចាប់កំណើតជាមនុស្ស យើងត្រូវតែឈរក្រោកឡើង។ គ្រីស្តបរិស័ទយើងមិនអាចទៅជាមនុស្សដែលអង្គុយខ្ជិល ផ្ទុយទៅវិញយើងជាមនុស្សដែលចេញធ្វើដំណើរ។ ហោរាចារ្យ ជាគំរូមួយដ៏អស្ចារ្យដោយសារពួកគេមិនគោរពព្រះជាម្ចាស់ទេ ជាមនុស្សដែលមានចំណេះដឹងល្អ ដែលស្រាវជ្រាវច្រើនទាំងផ្កាយ ទាំងព្រះអាទិត្យ ទាំងព្រះច័ន្ទ ប៉ុន្តែហិរាចារ្យសុខចិត្តចេញធ្វើដំណើរដើម្បីទៅរកអ្វី? នេះជាអ្វីដែលយើងត្រូវគិត។ សម្រាប់យើងជាគ្រីស្តបរិស័ទ យើងធ្វើដំណើរចេញពីផ្ទះដើម្បីទៅរកអ្វី?។ មិនមែនយើងចេញទៅរកទស្សនៈមួយ រកគំនិតមួយ មិនមែនទៅរកអ្វីដែលយើងមានច្បាស់ ប៉ុន្តែយើងទៅរកពន្លឺ។ នៅក្នុងអត្ថបទទីមួយ "**សេរីរុងរឿងរបស់ព្រះអម្ចាស់ភ្លឺមករកអ្នកដូចថ្ងៃនេះ**" ហេតុនេះហើយហោរាចារ្យចេញធ្វើដំណើរដើម្បីទៅរកពន្លឺ ប៉ុន្តែមិនមែនពន្លឺធម្មតា គឺពន្លឺដែលអាចបំភ្លឺជីវិតជីវិតរបស់យើងរៀងៗខ្លួន បន្លឺដ៏ពិសេសដែលគេយល់ហើយជាមូលហេតុពេលគេដល់ក្រុងយេរូសាឡឹមគេសួរថា **ព្រះមហាក្សត្ររបស់ជនជាតិយូដា ដែលទើបនឹងប្រសូតគង់នៅឯណា?។** សំនួររបស់គេ មិនមែនជាសំនួរដែលបំពេញគោលបំណងមួយនៅក្នុងជីវិតរបស់គេ ប៉ុន្តែជាសំនួរដ៏សំខាន់បំផុតសម្រាប់យើងជាគ្រីស្តបរិស័ទ ជាសំនួរសម្រាប់មនុស្សនៅក្នុងពិភពលោកទាំងមូល។ យើងត្រូវតែទៅរកព្រះជាម្ចាស់ដែលណែនាំបំភ្លឺជីវិតរបស់យើង ដោយដឹងថាយើងមិនទានបានរកច្បាស់លាស់។ ពេលនោះស្តេចហេរ៉ូដ និងប្រជាជនគេចង់ទៅមើលដែរ គេមានចម្លើយតាមពាក្យរបស់ព្យាការីថាព្រះយេស៊ូប្រសូតនៅភូមិបេថ្លេហឹម គេដឹងប៉ុន្តែគេមិនសុខចិត្តចេញធ្វើដំណើរដើម្បីទៅមើលព្រះយេស៊ូផ្ទាល់ភ្នែក។ ក្នុងខួរក្បាលគេ គេដឹងដោយសារគេអាននៅក្នុងគម្ពីរសម្ព័ន្ធមេត្រីចាស់ នៅភូមិបេថ្លេហឹនមានពន្លឺមួយដែលចេញបំភ្លឺពិភពលោកទាំងមូល

ដោយសង្គ្រោះមនុស្សលោក។ គេមិនចេញទៅរកព្រះយេស៊ូ មិនមែនដោយសារគេខ្ជិលតែដោយសារគេគ្មានគោលបំណងរកសេចក្តីពិតសម្រាប់ជីវិតរបស់គេ មិនមែនដោយសារគេជាមនុស្សអសកម្ម ប៉ុន្តែនៅក្នុងចិត្តគេ គេមិនចង់ឃើញពន្លឺដែលបំភ្លឺភាពងងឹត អំពើបាបរបស់គេ គេមានគោលបំណងតែមួយគឺចាប់ពន្លឺនេះដើម្បីសម្លាប់។ ប៉ុន្មានថ្ងៃក្រោយមក ស្តេចហេរ៉ូដចេញបញ្ជាឲ្យសម្លាប់កូនង៉ែតទាំងអស់ដែលបានកើតស្របាលគ្នាជាមួយព្រះយេស៊ូ ដោយសង្ឃឹមថាក្នុងចំណោមកូនង៉ែតនេះមានព្រះយេស៊ូដែរ។ តែហោរាចារ្យ បានសុខចិត្តធ្វើដំណើរនៅពេលគេឃើញផ្កាយនេះដោយសារគេចង់ទទួលពន្លឺសម្រាប់ជីវិតរបស់គេ គេមិនទាន់ច្បាស់ពន្លឺជាអ្វី? ប៉ុន្តែគេចេញធ្វើដំណើរ។ សម្រាប់ជីវិតរបស់យើងជាគ្រីស្តបរិស័ទ ពីមួយថ្ងៃទៅមួយថ្ងៃយើងត្រូវតែចេញពីផ្ទះរបស់យើងដើម្បីចេញធ្វើដំណើរស្វែងរកពន្លឺដែលបំភ្លឺជីវិតរបស់យើង។ យើងត្រូវសួរខ្លួនឯងថា **តើយើងមានគោលបំណងជួបជាមួយព្រះយេស៊ូពិតឬទេ? តើយើងមានគោលបំណងទទួលពន្លឺដើម្បីបំភ្លឺជីវិតរបស់យើងពិតឬទេ? តើយើងមានគោលបំណងទៅរកព្រះមហាក្សត្រដែលទើបនឹងប្រសូតឬទេ? តើព្រះយេស៊ូជាព្រះមហាក្សត្រនេះប្រសូតនៅឯណា?** ដើម្បីឲ្យយើងចេញធ្វើដំណើរដើម្បីទៅរក។ ហោរាចារ្យ គេចេញទៅរកព្រះមហាក្សត្រមួយយ៉ាងពិសេស គេចង់មើលដើម្បីណែនាំឲ្យគេភ្ញាក់ **កាលហោរាចារ្យទាំងនោះឃើញផ្កាយគេសប្បាយចិត្តពន់ប្រមាណ** ដោយសារគេរកឃើញកន្លែងដែលព្រះសង្គ្រោះប្រសូតហើយ។ គេចូលទៅក្នុងផ្ទះ គេឃើញព្រះឱរសគង់នៅជាមួយនាងម៉ារីជាមាតានៅក្នុងក្រោលសត្វ។ នេះជាព្រះមហាក្សត្រ ដែលពួកហោរាចារ្យបានសុខចិត្តធ្វើដំណើរស្វែងរកយូរថ្ងៃដែលព្រះមហាក្សត្រនេះបានប្រសូតនៅកន្លែងធម្មតាសាមញ្ញដល់កំពូល។ ពេលគេឃើញ គេមិនឆ្ងល់ គេមិនភ្ញាក់ គេមិនរត់ទៅវិញ ហោរាចារ្យដែលមានឋានៈនិងចំណេះដឹងខ្ពស់ គេនាំគ្នាក្រាបថ្វាយបង្គំព្រះអង្គ ដោយសារគេរកឃើញព្រះយេស៊ូ។ គេដឹងថាឱរសនេះប្រសូតនៅក្នុងក្រោលសត្វជាព្រះសង្គ្រោះដែលអាចសង្គ្រោះមនុស្សទាំងអស់ ហេតុនេះហើយគេនាំគ្នាក្រាបថ្វាយបង្គំព្រះអង្គ។

ដូច្នេះពេលយើងនឹកឃើញនេះ ហោរាចារ្យគេមិនទទ្ទឹងរងចាំកន្លែងពិសេស ប៉ុន្តែដូចគ្រូគង្វាលជាមនុស្សស្តែលសង្គមមិនចង់ទទួលស្គាល់ គេបានថ្វាយបង្គំដោយសារគេបានរកឃើញព្រះយេស៊ូនៅក្នុងជីវិតរបស់គេ ដែលណែនាំឲ្យគេមានអំណរសប្បាយយ៉ាងខ្លាំង។ សម្រាប់យើងជាពេលវេលាដើម្បីថ្វាយបង្គំដល់ព្រះយេស៊ូ ជាពេលវេលាដើម្បីមានអំណរសប្បាយដូចហោរាចារ្យ ជាពេលវេលាដើម្បីចេញពីផ្ទះរបស់យើងទៅចូលក្នុងផ្ទះរបស់ព្រះយេស៊ូ ជាពេលវេលាដើម្បីចេញពីមន្ទីរឃុំឃាំងនៅក្នុងជីវិតរបស់យើងដើម្បីរកឃើញសេរីភាពនៅក្នុងព្រះគ្រីស្ត ជាពេលវេលាដើម្បីសម្លឹងមើលព្រះយេស៊ូ ព្រះនាងម៉ារី នឹងលោកយ៉ូសែប ដែលជាគ្រួសារដ៏សុខសាន្តដោយណែនាំឲ្យយើងរៀងៗខ្លួនទទួលសេចក្តីសុខសាន្តសម្រាប់ជីវិតរបស់យើងដែរ។

ថ្ងៃនេះព្រះសហគមន៍អញ្ជើញមនុស្សទាំងអស់ ដែលមានសិទ្ធិចូលរួមទទួលមរតក មានសិទ្ធិចូលរួមក្នុងព្រះកាយតែមួយ មានសិទ្ធិទទួលព្រះពរតាមព្រះបន្ទូលសន្យារួមជាមួយសាសន៍អ៊ីស្រាអែល យើងមានសិទ្ធិទទួលព្រហសង្គ្រោះនៅក្នុងជីវិតរបស់យើង។ ប៉ុន្តែស៊ីសងយើងរៀងៗខ្លួន ឲ្យយើងធ្វើដូចហោរាចារ្យដោយសុខចិត្តចេញទៅរកព្រះយេស៊ូ នៅក្នុងសង្គមរបស់យើងបច្ចុប្បន្ននេះ រកឃើញព្រះយេស៊ូនៅក្នុងបងប្អូនឯទៀតៗ។ **នៅក្នុងព្រះវិហារ នៅក្នុងព្រះកាយ នៅក្នុងព្រះបន្ទូលដែលយើងស្ដាប់ នៅក្នុងដួងចិត្តរបស់យើង ប្រសិនបើយើងមិនចេញធ្វើដំណើរយើងមើលមិនឃើញព្រះយេស៊ូទេ នៅតាមផ្លូវមានព្រះយេស៊ូច្រើនណាស់ដែលកំពុងរងចាំ ដែលកំពុងស្រេកទឹក ដែលកំពុងសុំឲ្យយើងមើលព្រះអង្គ។** ដូច្នេះឲ្យយើងមូលអារម្មណ៍នៅក្នុងចិត្តរបស់យើង ដើម្បីទទួលជីវិតថ្មីរួមជាមួយព្រះយេស៊ូដែលជាពន្លឺ ឲ្យយើងសុខចិត្តក្រាបថ្វាយបង្គំដូចហោរាចារ្យ ដើម្បីណែនាំឲ្យពិភពលោករបស់យើងទៅជាពិភពថ្មី។

ឆ្នាំ២០១៧ជាឱកាសមួយ ដើម្បីឲ្យព្រះសហគមន៍របស់យើងគិតអំពីក្រុមគ្រួសារ ជាឱកាសមួយដើម្បីសម្លឹងមើលព្រះយេស៊ូ ព្រះនាងម៉ារី លោកយ៉ូសែប ដែលជាគ្រួសារដ៏វិសុទ្ធ។ យើងទទួលពន្លឺពីគ្រួសារដ៏វិសុទ្ធ ដើម្បីរកឃើញសេចក្ដីសុខនៅក្នុងជីវិតរៀងៗខ្លួន ដោយដឹងថាជីវិតរបស់យើងមានទុក្ខលំបាកច្រើនណាស់ ជីវិតរបស់យើងមានបញ្ហាច្រើនណាស់។ ប៉ុន្តែយើងដឹងថា យើងមានសេចក្ដីសង្ឃឹមទៀតដូចហោរាចារ្យយើងត្រូវតែចេញធ្វើដំណើរជានិច្ច ដើម្បីរកឃើញពន្លឺដែលបំភ្លឺជីវិតរបស់យើងរៀងៗខ្លួន។ ក្រោយមកទទួលហើយ យើងមិនទុកសម្រាប់យើងតែប៉ុណ្ណឹង ហោរាចារ្យចេញធ្វើដំណើរទៀត ដើម្បីចែករំលែកជាមួយមនុស្សឯទៀតៗ អំពីពន្លឺដែលយើងបានទទួល ដើម្បីឲ្យអ្នកដទៃមានឱកាសរកឃើញពន្លឺសម្រាប់ជីវិតរបស់គេដែរ។ ឆ្នាំនេះយើងយកចិត្តទុកដាក់ដើម្បីក្រាបថ្វាយបង្គំជានិច្ច យើងអោនខ្លួនដើម្បីទទួលព្រះយេស៊ូដែលជាជីវិត ដែលគង់នៅក្នុងបងប្អូនឯទៀតៗដែលកំពុងស្រេកទឹក។

សូមព្រះជាម្ចាស់គង់នៅជាមួយយើង ដើម្បីឲ្យយើងធ្វើដំណើរយ៉ាងសុខសាន្តនៅក្នុងដួងចិត្តរបស់យើង ឲ្យយើងសុខចិត្តចេញដើម្បីដើរតាមផ្កាយដែលភ្លឺដ៏ត្រចះត្រចង់។ អាម៉ែន។